# បឋមអប់រំខ្លី

## ស្តីអំពីៈ"ជីវិតរស់នៅ ត្រូវអាស្រ័យព្រះធម៌"

បុគ្គលគ្រប់រូប ដែលបានឧប្បត្តិឡើងមកសុទ្ធតែត្រូវការនូវខ្លឹមសាររបស់ព្រះធម៌ ពីព្រោះថាជីវិតរបស់មនុស្សយើងគ្រប់ៗរូប សុទ្ធតែជួបនូវរឿងរ៉ាវមិនចេះចប់មិនចេះហើយ ផុតពីរឿងនេះដល់រឿងនោះម្តង គឺថាជាការស្មុគស្មាញ បណ្តាញទុក្ខប្របូកប្របល់ខ្វល់ខ្វាយយ៉ាងខ្លាំងបំផុត ចំពោះរឿងជីវិតនេះ ។ មកពីរូបរបស់យើងម្នាក់ៗគឺសុទ្ធតែជាសម្បុកនៃទុក្ខទាំងអស់ ក៏អាចស្វែងយល់បានថាជាកម្មវិបាកផ្សេងៗជាដើម ។ ដោយសារហេតុតែជីវិត ចេះតែជួបពើបប្រទះនូវរឿងរ៉ាវស្មុគស្មាញ យ៉ាងនេះហើយ

ទើបមានបុគ្គលម្នាក់ សុខចិត្តលះបង់ចោលនូវទ្រព្យ សម្បត្តិ ប្រពន្ធកូនដោយមិនស្តាយសូម្បីបន្តិចសោះ ប្រៀបបីដូចជាបុគ្គលអ្នកស្តោះទឹកមាត់ចោល ហើយ ដើរចេញទៅដោយមិនស្តាយយ៉ាងនោះឯង ។ លុះ បុគ្គលនោះបានខិតខំបំពេញបារមីអស់រយៈកាល ៤ អសង្ខៃយ្យ កម្រៃ១សែនកប្បដើម្បីបានត្រាស់ដឹងជា ព្រះសម្មាសម្ពុទ្ធលុះត្រាស់ដឹងហើយ ព្រះអង្គបាន ,



ប្រកាសប្រាប់នូវរូបមន្តយ៉ាងពិសេសបំផុត ដែលមានចំនួន៨៤.០០០ព្រះធម្មក្ខន្ធ ដែលមានប្រជាជនយ៉ាងច្រើនបានហៅថាព្រះធម៌ ឬក៏ព្រះពុទ្ធសាសនានេះឯង ។ ហើយរូបមន្តនោះ ទៀតសោត គឺជាផែនទីដ៏ជាក់លាក់ពិតប្រាកដមួយ នៃព្រះពុទ្ធសាសនាដែលអាចដឹកនាំចម្លងសត្វលោក ឲ្យឆ្លងផុតចាកសេចក្តីទុក្ខវេទនាបាន ដើម្បីជួយស្រោចស្រង់នូវបុគ្គលគ្រប់រូប ដែលជាអ្នកប្រតិបត្តិតាមដោយល្អឲ្យរួចពីរណ្តៅនៃសេចក្តីទុក្ខ ឆ្ពោះទៅកាន់ទីបរមសុខពោលគឺព្រះនិព្វានបាន ។ ដូច្នេះ ក្នុងបញ្ហានេះផងដែរយើងអាចចោទសួរ និងដោះស្រាយបានតាមការសង្កេតនូវជីវិតរបស់ជនគ្រប់វ័យ ដែលជាអ្នកប្រតិបត្តិតាមដោយល្អ មិនថាតែអតីតៈ បច្ចុប្បន្ននិងអនាគតនោះទេ ។ ជីវិតនេះផងដែរ ប្រសិនបើយើងរស់តែសប្បាយក្មេងខ្លួននោះ ផលលំបាក

នឹងអាចហុចឲ្យយើងជាក់ជាមិនខានបើយើងធ្វើឲ្យ ,ប្រាសចាក**សតិ**នេះ ក៏អាចធ្វើឲ្យយើងហ្នឹងធ្លាក់ចុះគន្លងដែលមិនល្អ ដែលបុគ្គលពាលតែងតែប្រព្រឹត្ត



ធ្វើ អាចនាំយើងហ្នឹងឲ្យប្រាសចាកនូវព្រះធម៌ ដ៏បរិសុទ្ធថ្លាបើយើងធ្វើឲ្យប្រាសចាក ,**ហិរិនិងឱត្តប្បៈ** ក៏អាចនាំជីវិតយើងហ្នឹងឲ្យសៅហ្មង ប្រព្រឹត្តតែអំពើមិនល្អផ្សេងៗដែលសង្គមគេស្អប់ខ្ពើម, បើប្រព្រឹត្តប្រាសចាក**បញ្ញា** ក៏ប្រៀបបីដូចជាជីវិតនេះគ្មានតម្លៃអ្វីសោះ គឺងងឹតងងុលទៅក្នុងផ្លូវ**មិច្ឆាទិដ្ឋិ** ហើយមិនបានដឹងច្បាស់នូវអ្វីដែលជាប្រយោជន៍ និងមិន

ជាប្រយោជន៍គ្មានខ្លឹមសារអ្វីបន្តិចសោះឡើយ ,
ហើយបើបាត់បង់នូវ**វីរិយៈ** គឺសេចក្ដីព្យាយាមនេះ
ហើយ ក៏អាចធ្វើឲ្យយើងហ្នឹងបាត់បង់នូវប្រយោជន៍
ដ៏ធំមួយទៅហើយ កាលណាតែយើងបាត់បង់នូវ
ប្រយោជន៍ដ៏សំខាន់មួយនេះហើយ ជីវិតរបស់យើង
នឹងអន់ថយយ៉ាងខ្លាំងជាទីបំផុត ដូច្នេះជីវិតនឹងមិន
អាចរកសេចក្ដីចម្រើនរុងរឿងបាន ក៏មិនអាចដកខ្លួន
ឲ្យរួចចាកពីរណ្ដៅនៃសេចក្ដីទុក្ខបានឡើយ បើយើង
ធ្វើឲ្យបាត់បង់នូវធម៌ពីរទៀត គឺ**មេត្តា**និង**ករុណា**នេះ
ជីវិតយើងនឹងកាចសាហាវយង់ឃ្នងជាទីបំផុត គ្មាន
អ្វីអាចរារាំងបានឡើយ ។ ដូច្នេះហើយ បានជាយើង
អាចសម្គាល់បានថាជីវិតរបស់បុគ្គលគ្រប់រូប ដែល
អាចប្រព្រឹត្តទៅបានដោយល្អ ក៏អាស្រ័យនូវព្រះធម៌
នេះឯង ជាគ្រឿងលម្អដែលអាចដឹកនាំមនុស្សយើង
គ្រប់គ្នាឲ្យប្រព្រឹត្តនូវព្រះធម៌ដ៏ល្អ ដែលបរិសុទ្ធស្អាត

និងទីបំផុតក៏អាចនាំយើងឲ្យរួចផុតចាកទុក្ខបាន។

## គតិគួរពិចារណា

អ្វីដែលយើងគ្រាន់តែឮ យើងនឹងភ្លេចទៅវិញ

យើងនឹងចងចាំ  អ្វីដែលយើងបានឃើញ

អ្វីដែលយើងបានធ្វើ យើងនឹងអាចចេះបាន៕



ចងក្រងដោយ សាមណេរ (អគ្គញ្ញាណោ)រួង ចេនឡា

ឧបាសាចារ្យ **លីប៊ុនលើង** ចានពិនិត្យ

និងផ្ទៀងផ្ទាត់កែសម្រួលសំណៅនេះ

លោកគ្រូព្រះមហាធម្មាលង្កាពោ ចាន់ សុជន
ប្រធានកម្មវិធីណាធីសំឡេងព្រះធម៌
វត្តប្រាសាទស្រះកណ្ដាល(ខ្ចាស់)
បានពិនិត្យ និងឯកភាព

ធ្វើនៅវត្តប្រាសាទស្រះកណ្ដាល(ខ្ចាស់)
ថ្ងៃ១៥រោច ខែផល្គុណ ព.ស.២៥៥៨
ត្រូវនឹងថ្ងៃព្រហស្បតិ៍ ទី១៩ ខែមីនា ឆ្នាំ២០១៥